ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ១៥៥៤ ព.ណ.ជ.ក.ព

ថ្ងៃច័ន្ទ ១៥កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០១៩

## សេចក្តីជូនដំណឹង

## ស្តីអំពីករណីក្រុមហ៊ុន GCG ASIA CO., LTD.

នាពេលថ្មីៗនេះមានករណីបុគ្គលបរទេសប្រើឈ្មោះក្រុមហ៊ុន GCG ASIA CO., LTD. បានយកឈ្មោះ និងរូបភាព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងយកឈ្មោះធនាគារជាតិនៃកម្ពុជា ទៅបង្ហោះក្នុងគេហទំព័ររបស់ខ្លួន ដោយអះអាងថាសម្តេចនឹងអញ្ជើញចូលរួមសម្ពោធកាត់ខ្សែបូក្រុមហ៊ុននៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩ ខាងមុខនេះ។ ពាក់ព័ន្ធដល់ការប្រើប្រាស់ឈ្មោះ GCG ASIA CO., LTD. ក្រសួងពាណិជ្ជកម្ម សូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា ក្រសួងបានចុះបញ្ជីក្រុមហ៊ុនឈ្មោះ ជីស៊ីជី អេស៊ា ឯ.ក GCG ASIA CO., LTD. អត្តលេខចុះបញ្ជី ០០០១៨២០៥ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ ដែលមានអាសយដ្ឋានទីស្នាក់ការនៅអគារ Intelligent Office Center (IOC) លេខ RO១ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ក្រុមហ៊ុននេះមានម្ចាស់ភាគហ៊ុនតែម្នាក់ និងជាអភិបាលក្រុមហ៊ុនដែលមានសញ្ជាតិខ្មែរ និងមានកម្មវត្ថុអាជីវកម្មពាក់ព័ន្ធនឹងអចលនទ្រព្យ សំណង់ នាំចេញនាំចូល សណ្ឋាគារ សេវាអប់រំ និងភោជនីយដ្ឋាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងពាណិជ្ជកម្មសូមបញ្ជាក់ជូនថា ក្រុមហ៊ុនឈ្មោះ ជីស៊ីជី អេស៊ា ឯ.ក GCG ASIA CO., LTD. ដែលចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មមិនមានការពាក់ព័ន្ធទៅនឹងករណីយកឈ្មោះ និងរូបភាព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងយកឈ្មោះធនាគារជាតិនៃកម្ពុជា ទៅបង្ហោះក្នុងគេហទំព័ររបស់ខ្លួននោះឡើយ គឺបុគ្គលបរទេសទេដែលបានប្រើប្រាស់ឈ្មោះក្រុមហ៊ុន GCG ASIA CO., LTD. ផ្សេង ដែលមិនមែនជាក្រុមហ៊ុនចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អាស្រ័យហេតុនេះ សូម សាធារណជនមេត្តា ជ្រាបជាព័ត៌មាន។

សូមអរគុណ!